ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

# សេចក្តីប្រកាសព័ត៌មាន

អ្នកនាំពាក្យក្រសួងការពារជាតិនៃព្រះរាជាណាចក្រកម្ពុជា មានការសោកស្តាយយ៉ាងក្រៃលែង ចំពោះសេចក្តីប្រកាសព័ត៌មានរបស់ស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា ដែលបានចោទប្រកាន់ថា មន្ត្រីយោធាកម្ពុជាពុំបានផ្តល់ភាពពេញលេញដល់ដំណើរទស្សនកិច្ចរបស់អនុព័ន្ធយោធាអាមេរិកទៅកាន់មូលដ្ឋានសមុទ្ររាម កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២១។

អ្នកនាំពាក្យក្រសួងការពារជាតិ សូមធ្វើការបំភ្លឺដល់សាធារណមតិជាតិ និងអន្តរជាតិ ដូចតទៅ៖

ក្រសួងការពារជាតិបានយកចិត្តទុកដាក់ រៀបចំឲ្យមានដំណើរទស្សកិច្ចដូចបានពោលខាងលើ តាមសេចក្តីសម្រេចដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានសន្យាជាមួយលោកស្រី Wendy Sherman អនុរដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិក កាលពីថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២១ និងស្របតាមសំណើរបស់អនុព័ន្ធយោធាអាមេរិកនៅកម្ពុជា លោកវរសេនីយ៍ឯក Marcus Ferrara។

នៅក្នុងអំឡុងពេលទស្សនកិច្ចនៅមូលដ្ឋានសមុទ្ររាម ក្រុមការងារសម្របសម្រួល បានព្យាយាមបំពេញបំណងរបស់ប្រតិភូអាមេរិក ដោយអនុលោមទៅតាមគោលការណ៍ដែលបានកំណត់ និងការព្រមព្រៀងគ្នា។ សកម្មភាពសំខាន់ៗមួយចំនួន រួមមាន ជំនួបពិភាក្សាការងារដែលស្នើដោយភាគីអាមេរិក មានរយៈពេលជាងមួយម៉ោង ការចុះទៅពិនិត្យមើលអាគារសង់ថ្មីពីរខ្នងសម្រាប់ការស្នាក់នៅរបស់កម្មករសំណង់ ដំណើរពិនិត្យមើលផែ និងនាវា របស់កងទ័ពជើងទឹក ការទស្សនារោងជាងដែលជាជំនួយរបស់ប្រទេសអូស្ត្រាលី ការធ្វើទស្សនកិច្ចនៅមន្ទីរ



វិថីហ្សកនីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ៖ ០២៣ ៨៨៣ ២៧៨ អ៊ីមែល៖ generalsec@mod.gov.kh

ពេទ្យ និងការធ្វើដំណើរទៅពិនិត្យមើលសំណង់ទីបញ្ជាការជួរមុខរបស់ គណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ នៅកោះព្រាប។ ដំណើរទស្សនកិច្ចទាំងមូល ដែលចាប់ផ្តើមពីម៉ោង៩ កន្លះ បានអូសបន្លាយអស់រយៈពេលប្រមាណ៣ម៉ោង។

តែទោះជាដូច្នេះក្តី ក្រៅពីទីកន្លែងទាំងប៉ុន្មានខាងលើ ដែលបានស្នើ និងបានឯកភាពគ្នា ភាគីអាមេរិកបានបង្កើតស៊ីណារីយ៉ូថ្មីភ្លាមៗ ដោយទាមទារចូលទៅមើលកន្លែងផ្សេងទៀត ដែលពុំមានការស្នើសុំពីមុនមក។ ដោយមើលឃើញភាពមិនប្រក្រតី និងយល់ឃើញអំពីការមិនគោរពចំពោះអធិបតេយ្យរបស់កម្ពុជា និងចេតនាធ្វើជាមិនយល់អំពីលក្ខណការណ៍របស់កងទ័ព ក្រុមការងារបានបដិសេធចំពោះសំណើថ្មីនេះ។ លើសពីនេះទៅទៀត អនុព័ន្ធយោធាអាមេរិក ហាក់បង្ហាញអំពីភាពមានៈ នៅក្នុងការជំនះចូលទៅកាន់ទីនោះ ប៉ុន្តែនៅតែមិនត្រូវបានអនុញ្ញាត។

ផ្អែកលើកត្តាទាំងអស់ខាងលើ ក្រសួងការពារជាតិ ចាត់ទុកប្រតិកម្មរបស់ស្ថានទូតសហរដ្ឋអាមេរិក ជាការព្យាយាមបង្កើតបញ្ហាថ្មី និងបំភ្លៃការពិត ដែលនាំឲ្យមានភាពល្អក់កករកាន់តែខ្លាំងឡើង ដល់ទំនាក់ទំនងយោធារវាងប្រទេសទាំងពីរ។ ក្រសួងការពារជាតិ ចាត់ទុកចំណាត់ការរបស់ក្រុមការងារសម្របសម្រួលដំណើរទស្សនកិច្ច ថាមានភាពត្រឹមត្រូវ និងប្រកបដោយវិជ្ជាជីវៈ។ ក្រសួងការពារជាតិស្នើសុំដោយទទូចដល់សហរដ្ឋអាមេរិក ឲ្យបញ្ឈប់ការបង្កើតស៊ីណារីយ៉ូថ្មីៗ ដែលនាំមកនូវភាពអវិជ្ជមាន និងសូមឲ្យគោរពដល់អធិបតេយ្យ និងលក្ខណការណ៍កងទ័ព របស់ព្រះរាជាណាចក្រកម្ពុជា។ ចំពោះសំណើធ្វើទស្សនកិច្ចនាពេលអនាគត ក្រសួងការពារជាតិនឹងពិចារណាយ៉ាងហ្មត់ចត់ តាមករណីនីមួយៗ។ តែទោះជាយ៉ាងណាក៏ដោយ ក្រសួងការពារជាតិសូមបញ្ជាក់ថា សកម្មភាពទាំងឡាយនៅក្នុងបរិវេណមូលដ្ឋានកងទ័ព ដែលបានទទួលការអនុញ្ញាត គឺជាការធ្វើទស្សនកិច្ច ពុំមែនជាការទៅធ្វើការត្រួតពិនិត្យ ឬឆែកឆេរនោះឡើយ។

ថ្ងៃសៅរ៍ ៣កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២១

ក្រសួងការពារជាតិ
MINISTRY OF NATIONAL DEFENSE

# Press Release

Translation

The Spokesman of the Ministry of National Defense of Cambodia regrets the release of media information by the United States of America's Embassy in Phnom Penh, accusing Cambodia military officers of refusing full access to Ream Naval Base during a visit of the U.S. Defense Attaché, on 11 June 2021.

The Spokesman of the Ministry of National Defense would like to clarify to the national and international public as follows:

The Ministry of National Defense was sincere when organizing the aforementioned visit in accordance with the noble decision of **Samdech Akka Moha Sena Padei Techo HUN SEN**, Prime Minister of the Kingdom of Cambodia. The Prime Minister reached an agreement with the U.S. Deputy Secretary of State, Wendy R. Sherman, on 1st June 2021 and the request for the visit of the Defense Attaché, Colonel Marcus Ferrara.

At Ream Naval Base, the Coordination Working Group endeavored to meet the requirements of the U.S. delegation according to directive guidelines and the mutual agreements. Some important activities including a meeting which lasted more than one hour, the visit to two newly-constructed buildings which serve as accommodation for laborers, touring the naval pier and ships, visiting an Australian-supported naval workshop, visiting a hospital and then proceeding to Koh Preap to see the construction of the new Tactical Command Headquarters of the National Committee for Maritime Security. The entire visit started at 0930hrs and lasted approximately 3 hours.

However, beyond the requested and agreed locations, the U.S. side created an immediate new scenario as they demanded to enter another place which was not included in the initial request. Aware of this irregularity and noting that Cambodia's sovereignty was not being respected, along with the intention to ignore the military classification, the Working Group refused this new demand. Moreover, the U.S. Defense Attaché persisted with this request, which again could not be granted.

Due to the above factors, the Ministry of National Defense regards the reaction of the U.S. Embassy as striving to create new problems and distorting the facts which could further negatively impacts the defense relationship between the two countries. The Ministry of National Defense regards all measures taken by the Coordination Working Group as correct and



George Dimitrov Street, Sangkat Mittapheap, Khan 7Makara, Phnom Penh, Cambodia. Tel/Fax: (855) 023 883 274 Email: generalsec@mod.gov.kh

professional. The Ministry of National Defense calls for the U.S. Embassy to cease the creation of new scenarios which bring about negativity and insists the U.S. respect Cambodia's sovereignty and military classification. For future requests, the Ministry of National Defense will thoroughly consider these on a case-by-case basis. However, the Ministry of National Defense affirms that all the approved activities conducted in military facilities are visits, not inspections or searches.

Phnom Penh, 12th June 2021